ថ្ងៃខែ៖ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧

កម្មវត្ថុ៖ បទបញ្ញត្តិនៃការចាក់ថ្នាំបង្ការរោគ

ក្រសួងសុខាភិបាលនៃរដ្ឋផិនស៊ីលវេនញ៉ា បានចេញបទបញ្ញត្តិនៃការចាក់ថ្នាំបង្ការរោគថ្មី សម្រាប់សិស្សដែលត្រូវចូលរៀន។ ការកែប្រែបទបញ្ញត្តិទាំងនេះនឹងចាប់ផ្តើមមានប្រសិទ្ធិភាពនៅ ខែសីហា ឆ្នាំ២០១៧ ហើយនឹងមានឥទ្ធិពលដល់សិស្សវិទ្យាល័យ របស់យើងទាំងអស់។ ទោះបីជាសិស្សរបស់យើងជាច្រើនទើបតែបានទទួលការចាក់ថ្នាំបង្ការរោគគ្រប់គ្រាន់តាមការតម្រូវក្នុងពេលថ្មីៗនេះក៏ដោយ នៅមានសិស្សជាច្រើនទៀតដែលត្រូវការការចាក់ថ្នាំបង្ការរោគបន្ថែមទៀត។ ខាងក្រោមនេះគឺជាតម្រូវការថ្មី៖

សិស្សគ្រប់ថ្នាក់**ទាំងអស់**ត្រូវការ៖

- ៤ ដង សម្រាប់ តេតាណុស ខាន់ស្លាក់ និង ក្អកមាន់, ១ ដង ក្រោយពេលមានអាយុ ៤ ឆ្នាំ
- ៤ ដង សម្រាប់ រោគទន់សរសៃ, ១ ដង ក្រោយពេលមានអាយុ ៤ ឆ្នាំ
- ២ ដង សម្រាប់ កញ្ជ្រិល សាលាទែន និង ស្អូច (MMR), ទាំង ២ ដង ត្រូវចាក់ក្រោយពេលមានអាយុ ១ ឆ្នាំ
- ២ ដង សម្រាប់ អុតស្វាយ ឬមានឯកសារបញ្ជាក់ថាមិនអាចមានរោគអុតស្វាយ, ទាំង ២ ដង ក្រោយពេលមានអាយុ ១ ឆ្នាំ
- ៣ ដង សម្រាប់ រោគថ្លើមប្រភេទ B

តម្រូវការនៃការចាក់ថ្នាំបង្ការរោគបន្ថែម សម្រាប់សិស្ស **ថ្នាក់ទី៧ ដល់ ថ្នាក់ទី១២៖**

- ២ ដង សម្រាប់ រោគរលាកស្រោមខួរ លើកទីមួយនៅពេលមានអាយុ ១១ ទៅ ១៥ ឆ្នាំ និងលើកទីពីរ នៅពេលមានអាយុ ១៦ ឆ្នាំ ឬនៅពេលចូលរៀនថ្នាក់ទី១២។ បើចាក់លើកទីមួយនៅពេលមានអាយុ ១៦ ឆ្នាំ ឬ លើសពីនេះ ត្រូវការចាក់តែម្តងទេ។
- ១ ដង សម្រាប់ តេតាណុស ខាន់ស្លាក់ និង ក្អកមាន់

សិស្សទាំងអស់ត្រូវចាក់ថ្នាំបង្ការរោគទាំងនេះឲ្យបានគ្រប់ចំនួន ឲ្យទាន់ថ្ងៃចាប់ផ្តើមឆ្នាំសិក្សា ២០១៧/១៨ ឬស្ថិតនៅក្រោមការថែទាំរបស់វេជ្ជបណ្ឌិត ដែលមានផែនការត្រូវចាក់ឲ្យបានគ្រប់ចំនួន។ នៅពេលត្រឡប់មករៀនវិញនៅសរទរដូវខាងមុខនេះ សូមប្រគល់ឯកសារនៃការចាក់ថ្នាំបង្ការរោគថ្មីៗ ឲ្យទៅគិលានុបដ្ឋាក។